# សំណេរអត្ថបទចូលរួមអបអរទិវាជាតិអំណាន

# លើកទី៥ ឆ្នាំ២០២០

## ក្រោមប្រធានបទ

## “ការតែងនិពន្ធក្នុងយុគសម័យទំនើប ( ឌីជីថល )”



រូបភាពតំណាង ប្រភព: https://csrd.asu.edu/DigitalWri

**ស្នេរអត្ថបទ* មិន ម៉ៅសំណាង**

* ប្រវត្តិរូបសង្ខេបៈ ខ្ញុំបាទឈ្មោះ  មិន ម៉ៅសំណាង មានទីកន្លែងកំណើតនៅភូមិទួលតាកែវ ឃុំពងទឹក ស្រុករំដួល ខេត្តស្វាយរៀង ។ ខ្ញុំបាទធ្លាប់សិក្សាកម្រិតថ្នាក់បរិញ្ញាត្រជំនាញអក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (២០១១- ២០១៥)។

បច្ចុប្បន្នខ្ញុំបម្រើការងារតួនាទីជាអ្នកសារព័ត៌មាន នៃស្ថានីយទូរទស្សន៍ ភី.អិន.អិន. ធ្លាប់មានពិសោធន៍ប្រាំពីរឆ្នាំក្នុងវិស័យសារព័ត៌មាននេះ ជាសមាជិកក្លឹបអ្នកកាសែតកម្ពុជា (CCJ)។ ចាប់ពីឆ្នាំ ២០១៣ - ២០១៧ ខ្ញុំធ្លាប់បម្រើការងារផ្នែកប្រព័ន្ធផ្សព្វផ្សាយនៅមណ្ឌលព័ត៌មានស្ត្រីកម្ពុជា(WMC) ។  ទូរស័ព្ទ ០១១ ៧៥១ ១០២, អ៊ីម៉ែល mao.samnangnews@gmail.com។

# មាតិកា


**១. សេចក្តីផ្តើម**............................................................ ០១

**២. តើអ្វីជាការតែងនិពន្ធក្នុងយុគសម័យទំនើប (ឌីជីថល)?** ............................ ០២

**៣. អ្នកអានក្នុងយុគសម័យឌីជីថល** ............................................ ០៥

**៤. អ្នកនិពន្ធ និង ការតែងនិពន្ធក្នុងសម័យឌីជីថល** ................................ ០៧

**៤.១ គោលបំណងនៃការតែងនិពន្ធក្នុងយុគសម័យឌីជីថល** ......................... ០៨

**៤.២ របៀបតែងនិពន្ធក្នុងយុគសម័យឌីជីថល** ...................................... ០៩

១. អត្ថបទត្រូវបរិយាយតាមលំដាប់លំដោយគំនិត ........................................ ១០

២. ប្រវែងអត្ថបទបទនិពន្ធ ............................................................ ១០

៣. ការប្រើប្រាស់រូបភាព............................................................ ១០

៤. ទីកន្លែងតែងនិពន្ធ.............................................................. ១០

៥. អំណះអំណាង និងតំណភ្ជាប់...................................................... ១០

៦. ឯកសារយោង និងកម្មសិទ្ធិបញ្ញា................................................... ១១

**៤.៣ ការបោះពុម្ពផ្សាយអត្ថបទតែងនិពន្ធក្នុងសម័យឌីជីថល**...................... ១១

**៥. សេចក្តីសន្និដ្ឋាន** ............................................................ ១២

ឯកសារយោង

# សំណេរអត្ថបទចូលរួមអបអរព្រានរង្វាន់ជាតិអំណាន
# លើកទី៥ ឆ្នាំ២០២០

## ក្រោមប្រធានបទ
## "ការតែងនិពន្ធក្នុងយុគសម័យទំនើប (ឌីជីថល)"

*ស្មេរអត្ថបទ មិន ម៉ៅសំណាង

### ១. សេចក្តីផ្តើម

បច្ចុប្បន្នការតែងនិពន្ធសំណេរគ្រប់ទម្រង់ ការប្រមូលចងក្រងឯកសារចាស់និងថ្មី ការបកប្រែបង្កើតជារូបរាងឯកសារថ្មីៗ រួមទាំងការបោះពុម្ពផ្សាយផ្សេងៗ មានទិដ្ឋភាពកាន់តែទូលំទូលាយសម្រាប់ប្រជាពលរដ្ឋកម្ពុជា។ ជារៀងរាល់ថ្ងៃមធ្យោបាយបង្កើតគំនិតច្នៃប្រឌិតថ្មី ឬនវានុវត្តន៍ក្នុងការតែងនិពន្ធកំពុងកើតមានជាបន្តបន្ទាប់ ខណៈវត្តមានឯកសារ និងស្នាដៃជាច្រើនមាននៅលើទីផ្សារអំនាន។ ស្នាដៃប្រលោមលោក, ស្នាដៃសារព័ត៌មាន, ព្រឹត្តិបត្រព័ត៌មាន, បទនិពន្ធឧស្សាហកថាជំនួយស្មារតី, សៀវភៅ, និងឯកសារផ្សេងៗជាច្រើន អ្នកអានក៏អាចស្វែងរកអានបាននៅតាមបណ្ណាគារ បណ្ណាល័យនៅតាមសាលារៀន តូបលក់សៀវភៅ នៅទីតាំងពិពណ៌នានា នៅតាមស្ថាប័នក្រសួងជំនាញ បណ្តាញសង្គម ជាពិសេសនៅលើគេហទំព័ររបស់ស្ថាប័ននីមួយៗ។

ទន្ទឹមគ្នានេះ បើទោះបីស្នាដៃតែងនិពន្ធខ្លះទាមទារឱ្យអ្នកអានត្រូវចំណាយប្រាក់ដើម្បីជាវ ឬទទួលបានដោយមិនគិតថ្លៃក៏ដោយ ក៏អ្នកអានចង់បានឯកសារងាយស្រួលអាន និងប្រើប្រាស់ដែរ។ ស្របគ្នានេះ បទនិពន្ធទាំងនោះត្រូវតែផ្តល់ព័ត៌មាននិងខ្លឹមសារច្បាស់លាស់, អ្នកអានចំណាយពេលតិចទទួលបានផលច្រើន, មានសិល្បៈនិងរចនាបថទាក់ទាញចិត្ត, អ្នកអានងាយស្រួលចល័ត ឬយកតាមខ្លួន ដែលសាកសមជាបទនិពន្ធថ្មីក្នុងយុគសម័យទំនើប បង្កើតឡើងសម្រាប់អ្នកអានសម័យឌីជីថល។

ត្បិតអ្នកនិពន្ធជាផលិតករគំនិតក្នុងសំណេរផ្តល់ដល់អ្នកអាន ប៉ុន្តែបទនិពន្ធនៅក្នុងរបត់យុគសម័យឌីជីថលមិនទាមទារគំនិងស្នូកស្នាញរបស់ផលិតករ ផ្តល់បន្តទៅដល់ការគិតពិចារណារបស់អ្នកអានឡើយ។ អ្នកអានសម័យទំនើបត្រូវការសំណេរទម្រង់ទំនើប ហើយនេះជារបត់នៃការអានរបស់មនុស្សសម័យថ្មី ស្របនឹងការរីកចម្រើនបច្ចេកវិទ្យាឌីជីថលនៅក្នុងសង្គម។ ដូច្នេះសំណួរត្រង់នេះ តើអ្វីជាការតែងនិពន្ធក្នុងយុគសម័យទំនើប? តើការតែងនិពន្ធនេះ ត្រូវធ្វើយ៉ាងដូចម្តេច? ហើយការតែងនិពន្ធនេះមានប្រយោជន៍អ្វីសម្រាប់អ្នកអាននៅក្នុងយុគសម័យឌីជីថល?

## ២. តើអ្វីជាការតែងនិពន្ធក្នុងយុគសម័យទំនើប (ឌីជីថល)?

ការតែងនិពន្ធ វាប្រៀបដូចជាលំហូរនៃការសម្តែងសិល្បៈមួយអាចធ្វើទស្សនិកជនជក់ចិត្តជាប់នឹងទស្សនីយភាពនៃសាច់រឿង សមត្ថភាពរបស់នាដ្យការីសម្តែង អមដោយការប្រគុំឧបករណ៍តន្ត្រីស៉េរ៉ើកស៊ីសង្វាក់គ្នា។ ការតែងនិពន្ធដែលល្អ ប្រៀបដូចជាទស្សនីយភាពសម្តែងសិល្បៈអស្ចារ្យកើតឡើង និងពោរពេញដោយការចងចាំ។ ការតែងនិពន្ធជាប្រភេទការងារមួយពឹងអាស្រ័យលើចំណេះដឹង, គំនិត, និងសេចក្តីស្រលាញ់របស់ស្នេរចំពោះប្រធានបទអ្វីមួយដែលចង់បង្ហាញ។ អ្នកនិពន្ធមានច្រើនប្រភេទ[1] ប៉ុន្តែបទនិពន្ធមួយដែលល្អ ត្រូវមានទាំងអត្ថន័យ, អត្ថរស, ព្រមទាំងអត្ថរូបហើយស្នេរត្រូវមានទេពកោសល្យ និងចេះប្រើសិល្បៈក្នុងការតែងនិពន្ធ។ យ៉ាងណានេះជាទ្រឹស្តី និងរបៀបតែងនិពន្ធតែប៉ុណ្ណោះ ប៉ុន្តែការពិតវាស្ថិតនៅទម្រង់ផ្សេងពីនេះ ។

ការតែងនិពន្ធក្នុងយុគសម័យទំនើប ឬការតែងនិពន្ធក្នុងយុគសម័យឌីជីថល គឺជារបៀបក្នុងការបង្កើតសំណេរមួយដោយប្រើប្រាស់ឧបករណ៍ឌីជីថល មានដូចជាកុំព្យូទ័រ, ស្មាតហ្វូន, អាយផេត, ផេបប្លេតជាដើម។ ការតែងនិពន្ធក្នុងយុគសម័យឌីជីថលមានចំណងជាប់យ៉ាងជិតស្និតនឹងរបៀបតែងនិពន្ធ ឬទ្រឹស្តីតែងនិពន្ធ ប៉ុន្តែវាមិនមែនជាការតែងសំណេរវែងហួរអន្លាយ ធ្វើអ្នកអានសម័យឌីជីថលធុញទ្រាន់អាននោះទេ។ អ្នកអានយុគសម័យឌីជីថលប្រើប្រាស់ឧបករណ៍អេឡិកត្រូនិក ឬអាននៅលើឌីជីថល ដូចជាអ្នកតែងនិពន្ធលើឌីជីថលដែរ។ ចំណុចខុសគ្នាត្រង់ថា ម្នាក់ជាអ្នកបង្កើតខ្លឹមសារនៅលើឌីជីថល ម្នាក់ជាអ្នកទទួលនិងអានខ្លឹមសារលើឧបករណ៍ឌីជីថល។

នៅកម្ពុជាមិនទាន់មានការកំណត់និយមន័យ "**ការតែងនិពន្ធក្នុងយុគសម័យឌីជីថល**" មានអត្ថន័យនិងខ្លឹមសារយ៉ាងណានោះទេ ប៉ុន្តែចរន្តនៃការប្រើប្រាស់ឌីជីថលកាន់តែទូលំទូលាយពីមួយថ្ងៃទៅមួយថ្ងៃ។ នៅពេលខ្លះ គ្រាន់តែប្រើប្រាស់ស្មាតហ្វូនមួយគ្រឿងដើម្បីបង្កើតអត្ថបទអ្វីមួយ, កត់ត្រាគំនិតយល់ឃើញ, ថតជាវីដេអូ, សរសេរព័ត៌មាន, តាក់តែងចម្រៀង, កំណាព្យ, រឿងខ្លី, ក៏អាចរាប់បានថាជាការតែងនិពន្ធនៅលើឌីជីថលបានដែរ។ ការតែងនិពន្ធនៅលើឌីជីថល ជាការសរសេរដោយមិនចាំបាច់ប្រើប៊ិចនិងក្រដាសទេ[2]។ ជាក់ស្តែង ហ្វេសប៊ុកបានក្លាយជាមធ្យោបាយចែកចាយនិងទទួលព័ត៌មានសំខាន់នៅកម្ពុជា។ បណ្តាញហ្វេសប៊ុកកំពុងក្លាយជាវេទិកានៃការតែងនិពន្ធ។

ទំព័រហ្វេសប៊ុកមានព័ត៌មានឌីជីថលជាច្រើនកំពុងផ្សព្វផ្សាយ និងចែករំលែកហូរហែ។ អ្នកប្រើប្រាស់ឌីជីថលតាមរយៈបណ្តាញសង្គមមួយនេះ ក៏អាចបង្កើតនិងទទួលបានខ្លឹមសារ ឬមាតិកានិពន្ធផ្សេងៗនៅលើហ្វេសប៊ុកបានយ៉ាងងាយស្រួលដែរ។ ចំណុចនេះ ក៏អាចចាត់ទុកការតែងនិពន្ធក្នុងយុគសម័យទំនើប ឬអ្នកនិពន្ធសម័យឌីជីថល។

---

[1] មើលលម្អិត "ចំណេះដឹងទូទៅ", (២០១៩), តើអ្នកតែងនិពន្ធមានប៉ុន្មានប្រភេទ?, តំណភ្ជាប់ https://www.khsearch.com/qna/16445 ។

[2] មើលលម្អិត "ការតែងនិពន្ធលើឌីជីថល (Digital Writing)", (២០១៣) តំណភ្ជាប់ http://w350digitalwriting.wikidot.com/ ។

តាមទិន្នន័យអ្នកប្រើប្រាស់បណ្តាញសង្គមហ្វេសប៊ុកនៅកម្ពុជារបស់គេហទំព័រ GeekinCambodia គិតត្រឹមឆ្នាំ ២០១៩ មានអ្នកប្រើហ្វេសប៊ុកចំនួន ៨.៨លានគណនីហ្វេសប៊ុក (Geek, ២០១៩)។ ផ្អែកតាមស្ថិតិនេះ បង្ហាញយ៉ាងច្បាស់ថា ចំនួនអ្នកប្រើប្រាស់ឌីជីថល (Facebook) នៅកម្ពុជាកំពុងកើនឡើងជាបន្តបន្ទាប់មានប្រមាណជាង ២លាន់នាក់ជារៀងរាល់ឆ្នាំ តួលេខនេះមិនរាប់បញ្ចូលបណ្តាញសង្គមផ្សេងៗឡើយ។







ចំនួន និង អាយុអ្នកប្រើប្រាស់ហ្វេសប៊ុក (គណនី) នៅកម្ពុជា គិតត្រឹមឆ្នាំ២០១៩ ប្រភពនិងតំភ្ជាប់គេហទំព័រ http://geeksincambodia.com ។

យោងតាមស្ថិតិបង្ហាញចំនួនអ្នកប្រើប្រាស់បណ្តាញសង្គមហ្វេសប៊ុកកាន់តែកើនឡើង មានន័យថា លទ្ធភាពប្រើប្រាស់អ៊ីធឺណេតរបស់ប្រជាពលរដ្ឋកម្ពុជាក៏កើនឡើងស្របគ្នាដែរ។ តាមរយៈទិន្នន័យនេះ ការតាក់តែងនិពន្ធសម័យឌីជីថល ក៏អាចរាប់បញ្ចូលបានទាំងការសរសេរខ្លឹមសារបង្ហោះលើអ៊ីធឺណេត មានគេហទំព័រ, ប្លុក, ហ្វេសប៊ុក, យូធូប, ឡាញ, អ៊ីនស្តាក្រាម, និងធ្វិកឃឺជាដើម។ ការសរសេរនៅលើអ៊ីនធឺណេតតាមរយៈបណ្តាញសង្គមមានឥទ្ធិពលយ៉ាងខ្លាំងចំពោះអ្នកអាន (សាធារណជន) ឬអ្នកប្រើប្រាស់បណ្តាញសង្គមក្នុងសម័យឌីជីថលនេះ ព្រោះមធ្យោបាយក្នុងការសរសេរតាក់តែងងាយស្រួល និងលឿនរហ័ស។




សំណេរព័ត៌មានលើហ្វេសប៊ុករបស់លោក ពុយ គា អ្នកសារព័ត៌មាន អំពីរឿងក្រៅឆាកនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៥ នៅទីក្រុងបាងកក ។




សំណេរបទចម្រៀងលើហ្វេសប៊ុករបស់លោក ម៉ៃ វឌ្ឍនា អ្នកនិពន្ធ អានលម្អិត បទសម្រស់ផ្កាល់ខ្ទួច ។

ការតែងនិពន្ធក្នុងយុគសម័យទំនើប បង្ហាញវត្ថុមាននិងខ្លឹមសារទាំងអស់លើឌីជីថល មានដូចជាអត្ថបទ, វីដេអូ, ចម្រៀង, រូបភាព សៀវភៅ, ព័ត៌មាន, និង Infographic (Digital Writing, ២០១៩)។ វិធីបង្ហាញស្នាដៃទាំងនេះអាចដាក់នៅក្នុង Google, Wikipedia, Amazon, Alibaba, Airbnb, Personal Blog, ព្រមទាំងនៅក្នុងបណ្តាញសង្គមគ្រប់ទម្រង់ (Social Media Platform)។ ដំណាក់កាលនិយាយពីការតែងនិពន្ធក្នុងយុគសម័យឌីជីថលនេះ ក៏ត្រូវគិតគូរទៅដល់ការរីកចម្រើនបច្ចេកវិទ្យានៅក្នុងសង្គមផងដែរ ពិសេសការរីកចម្រើនបច្ចេកវិទ្យាឌីជីថលនៅគ្រប់វិស័យក្នុងរបត់ដែលពិភពលោកកំពុងនិយាយអំពីបដិវត្តន៍ឧស្សាហកម្មទី៤។

ការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលកម្ពុជា រួមមានការអប់រំបែបឌីជីថល សេដ្ឋកិច្ចឌីជីថល, កសិកម្មឌីជីថល, សុខាភិបាលឌីជីថល, ទេសចរណ៍និងសេវាកម្មឌីជីថល, ជាចំណែកមួយដែលអនុញ្ញាតឱ្យស្នាដៃតែងនិពន្ធក្នុងយុគសម័យទំនើបកើតឡើងជាបន្តបន្ទាប់ដែរ។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនាពេលបច្ចុប្បន្ន ធ្វើឱ្យមនុស្ស ឬអ្នកប្រើប្រាស់កាន់តែស្វះស្វែងរកភាពងាយស្រួល បំប្លែងឯកសារចាស់ៗទៅជាឯកសារងាយស្រួលកាន់ ព្រមទាំងចល័តបានពីទីកន្លែងមួយទៅទីកន្លែងមួយ។ ជាក់ស្តែង អ្វីដែលមើលឃើញនាពេលនេះ វត្ថុមានទស្សនាវដ្តីកម្ពុជសុរិយា[3] ក្រៅពីបោះពុម្ពផ្សាយជាសៀវភៅ អ្នកអានអាចស្វែងរកអត្ថបទតាមរយៈតំណភ្ជាប់អេឡិកត្រូនិក (Link) ហើយសៀវភៅមួយចំនួន បានប្រែក្លាយរូបរាងរបស់ខ្លួនមកនៅលើឌីជីថល (ស្កេនបង្ហោះឡើងវិញ)។ លើសពីនេះ មានសៀវភៅចាស់ៗ និងស្នាដៃតែងនិពន្ធចាស់និងថ្មីៗជាច្រើន ក៏មានវត្តមានជាបណ្តើរៗនៅលើឌីជីថលផងដែរ។




ទស្សនាវដ្តីកម្ពុជសុរិយា បានស្កេនបង្ហោះលើបណ្តាញសង្គមហ្វេសប៊ុក សមាគមអ្នកអក្សរសិល្ប៍កម្ពុជា ឆ្នាំ២០១៩។




សៀវភៅរឿងនិទានសម្រាប់ថ្ងៃអាទិត្យនេះគឺអំពី មូសខ្លា បានស្កេនបង្ហោះលើបណ្តាញសង្គមហ្វេសប៊ុក កុមាររៀនកុមារចេះ ។

[3] ទស្សនាវដ្តី កម្ពុជសុរិយា ជាទស្សនាវដ្តី "អក្សរសាស្ត្រ ព្រះពុទ្ធសាសនា" បង្កើតដំបូងនៅវាំងគ.ស. ១៩២៥ ផ្សាយចេញពីព្រះរាជបណ្ណាល័យកម្ពុជា។

ទាំងនេះជាទិដ្ឋភាពជុំវិញការតែងនិពន្ធក្នុងយុគសម័យទំនើប ខណៈវត្តមានស្នាដៃចាស់និងថ្មីទាំងឡាយបានរត់មករស់នៅលើឌីជីថល។ ស្នាដៃនៅលើឌីជីថលអាចឱ្យអ្នកអានកាន់តែងាយស្រួលអាន, ងាយស្រួលស្វែងរកឯកសារ ឬព័ត៌មាន, ព្រមទាំងងាយស្រួលក្នុងចែករំលែកគំនិត។ ត្បិតឌីជីថលបានផ្ដល់ឱ្យស្នាដៃទាំងឡាយហាក់មានជីវិតរស់រវើក និងប្រែក្លាយខ្លួនពីសំណេរនៅលើសន្លឹកសៀវភៅ ទៅជាសំណេរអេឡិកត្រូនិកក៏ពិតមែន ប៉ុន្តែការតែងនិពន្ធទាំងអស់មិនសុទ្ធតែអាចធ្វើបាននៅលើឌីជីថលឡើយ។ ដើម្បីបង្កើតបានស្នាដៃតែងនិពន្ធថ្មីមួយនៅលើឌីជីថល ដាច់ខាតទាមទារឱ្យផលិតករត្រូវយល់ដឹងពីវិធីប្រើប្រាស់ឌីជីថល ឬអាចនិយាយម្យ៉ាងទៀតថា អក្ខរកម្មឌីជីថល[4]។

ជារួមមកវិញ ការតាក់តែងនិពន្ធនៅក្នុងយុគសម័យឌីជីថល មិនមែនជាការតែងនិពន្ធនៅលើសន្លឹកសៀវភៅដូចមុននោះទេ វាជាការតែងនិពន្ធសម័យទំនើប ឬបង្កើតខ្លឹមសារក្នុងទម្រង់ថ្មីដោយពឹងទៅលើបច្ចេកវិទ្យា និងឧបករណ៍ឌីជីថល។ ការតែងនិពន្ធក្នុងយុគសម័យឌីជីថល មានការបង្កើតវីដេអូ, សំឡេង, រូបភាព, និងសំណេរ, ដែលបម្រើដល់ការសិក្សាស្រាវជ្រាវ និងការកម្សាន្តរបស់មនុស្សនៅក្នុងសតវត្សរ៍ទី២១។ ដើម្បីមានលទ្ធភាព និងមានសមត្ថភាពតែងនិពន្ធនៅលើឌីជីថលក្នុងយុគទំនើបនេះ អ្នកនិពន្ធត្រូវមានមូលដ្ឋានចំណេះដឹង, បំណិនជីវិត, និងជំនាញច្បាស់លាស់បង្ហាញទៅកាន់អ្នកអាន អ្នកស្ដាប់ ឬអ្នកទស្សនា (Audience)។ លើសនេះ អ្នកនិពន្ធត្រូវដឹងពីវិធីសាស្ត្រតែងនិពន្ធនៅក្នុងសម័យឌីជីថល ស្គាល់ពីតម្រូវការ ឬចិត្តសាស្ត្ររបស់អ្នកអានសម័យទំនើប អ្នកនិពន្ធត្រូវមានក្រមសីលធម៌ និងឥរិយាបទថ្លៃថ្នូរក្នុងសង្គម។

## ៣. អ្នកអានក្នុងយុគសម័យឌីជីថល

អ្នកអានស្នាដៃសម័យឌីជីថល មិនខុសគ្នាពីអ្នកទទួលព័ត៌មានប្រចាំថ្ងៃតាមឌីជីថលឡើយ។ ក្នុងរបត់និយាយពីការបង្កើតខ្លឹមសារនៅលើឌីជីថលនៅពេលនេះ មធ្យោបាយអានសម័យទំនើបៗក៏មានច្រើនប្រភេទដែរ ដែលអ្នកអានអាចជ្រើសរើសបានតាមចិត្ត។ ការអានរបស់អ្នកអានសម័យទំនើប មានតាមរយៈ អ៊ី-លីប្រារី (E-Library), E-Book (អ៊ី-ប៊ុក),ឃីនដល (Kindle), កុំព្យូទ័រ (Computer), ស្មាតហ្វូន (Smart Phone), អ៊ីនធឺណេត (Internet), និងការបង្កើតព័ត៌មាននៅលើយូធូប (YouTube) ជាដើម។ ចំណុចសំខាន់ដែលអ្នកនិពន្ធ ត្រូវគិតដល់អ្នកអានជាចម្បងគឺរាល់បទនិពន្ធទាំងអស់ ឬការតែងអត្ថបទឡើង អាចសន្ទនាគ្នារវាងអ្នកនិពន្ធ, អ្នកអាន, និងសាធារណជនបានគ្រប់ពេលវេលា។ បច្ចុប្បន្នមានអត្ថបទ ខ្លឹមសារ បទនិពន្ធជាច្រើន ព័ត៌មានទូលំទូលាយ លឿនរហ័ស បានធ្វើអ្នកអានមានគំនិតបញ្ញាកាន់តែខ្ពស់។ កត្តានេះ ធ្វើឲ្យអ្នកនិពន្ធដែលចង់សម្រេចជោគជ័យស្នាដៃ ត្រូវតែមានគំនិតច្នៃប្រឌិតទាន់សម័យ ដូចគ្នានឹងអ្នកអានឌីជីថល។ ចំណែកការទទួលបានចំណេះដឹងរបស់មនុស្សក៏គ្មានដែនកំណត់ដែរ[5]។

---

[4] ពាក្យ "អក្ខរកម្មឌីជីថល" មានន័យថាលទ្ធភាពដែលអាចប្រើប្រាស់ឌីជីថល ឬបុគ្គលម្នាក់ៗអាចអាន សរសេរ និងទទួលយកព័ត៌មានដោយប្រើប្រាស់បច្ចេកវិទ្យា និងទម្រង់ឌីជីថល។ អានលម្អិតចុច "ហេតុអ្វីអក្ខរកម្មឌីជីថលមានសារសំខាន?" បោះពុម្ពដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០១៩ ។

[5] អត្ថបទ "តើនឹងមានអ្វីកើតឡើងប្រសិនបើចំណេះដឹងរបស់មនុស្សគ្មានដែនកំណត់?" លោក Maverick Baker, ឆ្នាំ២០១៨ ។

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ធ្លាប់មានប្រសាសន៍ថា របៀបទទួលចំណេះដឹងរបស់មនុស្សនៅក្នុងសតវត្សរ៍ទី២១នេះ មិនចាំបាច់ពឹងផ្អែកទាំងស្រុងលើការអានសៀវភៅតែមួយមុខនោះទេ។ មធ្យោបាយជាច្រើនដែលអ្នកសិក្សាអាចទទួលចំណេះដឹងបាន " (ដើម្បីទទួលបាន) ចំណេះដឹងមានរូបភាពច្រើន មានដូចជាអត្ថបទ, ជារូបភាព, វីដេអូ, ជាសំឡេង, ដែលពីមុនចំណេះដឹងមានតែនៅលើសៀវភៅ (អានសៀវភៅ) ចង់ដឹង ចង់ចេះ ត្រូវទៅបណ្ណាល័យមើលសៀវភៅ ឥឡូវនេះមិនដូចពីមុនទេ ហើយរបៀបរៀនរបស់យុវជនបច្ចុប្បន្នក៏ខុសពីមុនដែរ...[6]"។ អំនាននៅលើឌីជីថលនាពេលបច្ចុប្បន្ន ធ្វើអ្នកអានមានសេរីភាពច្រើនក្នុងការជ្រើសរើសអត្ថបទ ឬកំណត់ប្រភេទខ្លឹមសារណាមួយដែលពួកគេចង់បាន។ ពេលខ្លះ រូបភាពក៏អាចឱ្យអ្នកអានទទួលបានខ្លឹមសារគ្រប់គ្រាន់ពីសំណេរដែរ ព្រោះចំណង់ចំណូលចិត្តនិងរបៀបទទួលព័ត៌មានរបស់អ្នកអានខុសៗគ្នា ។




ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានប្រសាសន៍ នៅបាឋកថាសាធារណៈ[សម្រាប់កិច្ចសន្ទនា កម្ពុជាឧស្សាហកម្ម ៤.០](), ដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា, រូបភាព[ហ្វេសប៊ុកកិច្ចសន្ទនា កម្ពុជាឧស្សាហកម្ម ៤.០]() ។

អ្នកអានសម័យឌីជីថលមានសេរីភាពទទួលបានខ្លឹមសារព័ត៌មានច្រើន ច្បាស់លាស់ និងមានប្រយោជន៍ ជាជាងចំណាយពេលអានច្រើនទទួលបានខ្លឹមសារតិច។ ដូច្នេះការតែងនិពន្ធក្នុងសម័យទំនើប ក៏មិនខុសពីរបៀបសេរសេរព័ត៌មានផ្សព្វផ្សាយនៅលើកាសែត, វិទ្យុ, ទូរទស្សន៍, និងអនឡាញដែរ។ អ្នកអានចង់បាននោះគឺ "អត្ថបទខ្លី, មានខ្លឹមសារច្បាស់លាស់, និងមានទំនុកចិត្ត"។ ការប្រើប្រាស់ឧបករណ៍ឌីជីថលដើម្បីអាន ផ្ទុយពីអំណានលើសន្លឹកសៀវភៅ ព្រោះអារម្មណ៍របស់អ្នកអានប្រើឧបករណ៍អេឡិកត្រូនិក អាចប្រែប្រួលផ្លាស់ប្តូរប្រធានបទភ្លាមៗ ប្រសិនបើគេគិតថាខ្លឹមសារមួយទៀតសំខាន់ជាងខ្លឹមសារកំពុងអាន។ អ្នកអានមានអំណាចអាចប្រៀបធៀប វិនិច្ឆ័យព័ត៌មាន ឬខ្លឹមសារអត្ថបទរបស់អ្នកដោយខ្លួនឯងបាន។ លើសពីនេះ អ្នកអានតែងត្រូវការព័ត៌មានបន្ថែមលើអត្ថបទ ចង់ដឹងប្រភពព័ត៌មានជាក់លាក់ ដែលប្រការនេះស្មើរ ឬអ្នកនិពន្ធចាំបាច់ត្រូវធានានិងមានទំនួលខុសត្រូវចំពោះអ្នកអានរបស់ខ្លួន។

---

[6] ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានប្រសាសន៍នៅបាឋកថាសាធារណៈសម្រាប់កិច្ចសន្ទនា កម្ពុជាឧស្សាហកម្ម ៤.០ ក្រោមប្រធានបទ «[អក្ខរកម្មឌីជីថលក្នុងបរិបទកម្ពុជាឧស្សាហកម្ម ៤.០]()» ថ្ងៃទី០៨ តុលា ២០១៩, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

## ៤. អ្នកនិពន្ធ និង ការតែងនិពន្ធក្នុងសម័យឌីជីថល

នៅពេលនិយាយពីរបៀបតែងនិពន្ធក្នុងសម័យឌីជីថល ទំនងមិនទាន់មានក្បួន ឬវិធីសាស្ត្រតែងនិពន្ធរបៀបនេះចងក្រងបង្កើតឡើងនៅកម្ពុជានាពេលបច្ចុប្បន្នឡើយ។ អនាគតប្រាកដជាមានជាក់ជាពុំខានដោយយោងទៅលើការរីកចម្រើននៃបច្ចេកវិទ្យាថ្មីៗ នៅក្នុងបរិបទកម្ពុជាកំពុងនិយាយពីវត្តមានបដិវត្តន៍ឧស្សាហកម្មទី៤ និងការត្រៀមខ្លួនសម្រាប់បដិវត្តន៍ឧស្សាហកម្មទី៤[7] នឹងចូលមកដល់នាពេលខាងមុខ។

ការវិវត្តន៍នៃបច្ចេកវិទ្យាឌីជីថលថ្មីៗនៅក្នុងសង្គម ចំណេះដឹង ព្រមទាំងបញ្ញារបស់មនុស្សរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ ការកំណត់ពីវិធីសាស្ត្រតែងនិពន្ធក្នុងយុគសម័យបច្ចេកវិទ្យា ក៏អាចប្រែប្រួលទៅតាមនោះដែរ។ ឧទាហរណ៍ជាក់ស្តែង និយាយការផលិតព័ត៌មាននៅលើប្រព័ន្ធផ្សព្វផ្សាយ (Media) បច្ចុប្បន្នមានការប្រែប្រួលគួរឱ្យកត់សម្គាល់ស្របតាមតម្រូវការរបស់អ្នកអាន។ ទម្រង់ប្រព័ន្ធផ្សព្វផ្សាយចម្រុះ ឬហៅថា Multimedia កំពុងពេញនិយមសម្រាប់អ្នកសារព័ត៌មាន និងអ្នកអាន ដោយទម្រង់ផលិតព័ត៌មានថ្មីនេះបានប្រាប់បញ្ចូលគ្នាក្នុងអត្ថបទតែមួយ រវាងសំណេរ (Text), សំឡេង (Audio), រូបភាព (Picture), វីដេអូ (Video), ក្រាហ្វិក (Graphic), និងតំណភ្ជាប់ព័ត៌មានផ្សេងៗពីមួយទៅមួយ កាន់តែងាយស្រួលសម្រាប់អ្នកអាន។




ខ្សែសង្វាក់នៃការផលិតព័ត៌មានលើប្រព័ន្ធផ្សព្វផ្សាយសម័យទំនើប (ឌីជីថល)
បានប្រាប់បញ្ចូលគ្នាពីគ្រប់ទម្រង់ផ្សព្វផ្សាយទាំងអស់ ហៅថា ប្រព័ន្ធផ្សព្វផ្សាយចម្រុះ (Multimedia), រូបភាព ម៉ៅ សំណាង ។

[7]បញ្ញត្តិបដិវត្តន៍ឧស្សាហកម្មទី៤ ឬ "ឧស្សាហកម្ម៤.0" ត្រូវបានកំណត់ឡើងនៅក្នុងពិព័រណ៍ធំមួយឈ្មោះ Hannover ក្នុងឆ្នាំ២០១១ នៅប្រទេសអាល្លឺម៉ង់ ដោយសម្តៅលើការផ្លាស់ប្តូរក្នុងខ្សែសង្វាក់តម្លៃសាកល ដែលកើតឡើងដោយកិច្ចសហប្រតិបត្តការរវាងប្រព័ន្ធនិម្មិត និងរូបសាស្ត្រនៃផលិតកម្មក្នុង "រោងចក្រឆ្លាតវៃ"។ សូមអានលម្អិតអត្ថបទជំនួយស្មារតី "បដិវត្តន៍ឧស្សាហកម្មទី៤" បោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

តាមរយៈឧទាហរណ៍នេះ អាចបញ្ជាក់បានថា គ្រប់បទនិពន្ធទាំងអស់នៅលើឌីជីថលអាចប្រែប្រួលទៅតាមតម្រូវការរបស់អ្នកអាន។ ចំណែកការតែងនិពន្ធក្នុងយុគសម័យឌីជីថល តម្រូវឱ្យអ្នកនិពន្ធម្នាក់ៗ មានគោលការណ៍ច្បាស់លាស់ក្នុងការតែងនិពន្ធដែលជាអត្តសញ្ញាណរបស់ខ្លួន បង្កើតឡើងដោយគំនិតច្នៃប្រឌិតថ្មី (Creative Idea)។ ក្នុងនោះ អ្នកនិពន្ធមាតិកា (Content Creator) ឬខ្លឹមសារផ្សេងៗត្រូវដឹងពីគោលបំណងនៃការតែងនិពន្ធរបស់ខ្លួន ដឹងពីរបៀបសរសេរ (តែងនិពន្ធ) មានអំណះអំណាងនិងប្រភពច្បាស់លាស់ និងគោរពច្បាប់កម្មសិទ្ធិបញ្ញាជាដើម។




ទម្រង់នៃការតែងនិពន្ធសំណេរ និង ព័ត៌មាននៅលើប្រព័ន្ធផ្សព្វផ្សាយសម័យទំនើប (ឌីជីថល)
របៀបសរសេរព័ត៌មានសម័យឌីជីថល, រូបភាព ម៉ៅ សំណាង ។

## ៤.១ គោលបំណងនៃការតែងនិពន្ធក្នុងយុគសម័យឌីជីថល

គោលបំណងនៃសំណេរ ឬគោលបំណងបង្កើតបទនិពន្ធមួយច្បាស់លាស់ ជាចំណុចស្នូលសំខាន់ដែលអ្នកចង់តែងនិពន្ធត្រូវគិតមុនគេ។ ដើម្បីបង្កើតគោលបំណងជាក់លាក់សម្រាប់បទនិពន្ធរបស់ខ្លួន អ្នកនិពន្ធខ្លឹមសារត្រូវឆ្លើយនឹងសំណួរមួយចំនួន ថាតើខ្លឹមសារនៃបទនិពន្ធនោះបង្កើតឡើងមានគោលដៅអ្វី? តើមានប្រយោជន៍អ្វីសម្រាប់អ្នកអាន? តើវាជាស្នាដៃថ្មីដែរឬទេ? តើបទនិពន្ធនេះប្រើជាទម្រង់អ្វីនៅលើឌីជីថល? តើនរណាអ្នកអាន? នៅពេលកំណត់ច្បាស់ហើយ នោះការអភិវឌ្ឍន៍ប្រធានបទនឹងដំណើរការដោយរលូនជាក់ពុំខាន។

ចំណុចគួរកត់សម្គាល់មួយក្នុងការកំណត់គោលបំណង នៃការតែងនិពន្ធក្នុងយុគសម័យឌីជីថល និពន្ធត្រូវប្រាកដខ្លួនឯងថា ស្នាដៃរបស់ខ្លួនកំពុងរៀបចំតែងនិពន្ធជារឿងថ្មី, ប្លែក, និងមានលក្ខណៈពិសេសជាងស្នាដៃផ្សេងៗ, ហើយខ្លឹមសារផ្តល់ព័ត៌មាន ចំណេះដឹង និងការកំសាន្តដល់អ្នកអាន។ បច្ចុប្បន្នមានមាតិកាព័ត៌មានជាច្រើនដាក់នៅលើអ៊ីន

ធីណេត ប្រសិនបើសិនខ្លឹមសារនៃមាតិកានោះមិនអាចទាក់ទាញចិត្តអ្នកអាន អ្នកស្តាប់ អ្នកទស្សនា ច្បាស់ណាស់មាតិកានិងខ្លឹមសារនោះកប់នៅក្នុងអ៊ីនធីណេតគ្មានអ្នកចែករំលែកបន្តឡើយ។ បទនិពន្ធមួយដែលមានខ្លឹមសារល្អសម្រាប់អ្នកអាន កើតឡើងដោយការប្រមូលផ្តុំគំនិតនិងខ្លឹមសារពីគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់។ ខ្លឹមសារបទនិពន្ធល្អរាប់ទាំងការប្រើប្រាស់ពាក្យពេចន៍ ឃ្លា ប្រយោគ រចនាបថ គំនិតច្នៃប្រឌិតថ្មីៗ គំនិងសមហេតុផល អំណះអំណាង និងទឡ្ហីករណ៍ច្បាស់លាស់។

ជាក់ស្តែងអត្ថបទមួយនិយាយពី "អ្វីគ្រប់យ៉ាងដែលអ្នកគួរដឹងអំពីប្រព័ន្ធ 5G" បានពន្យល់តាមលំដាប់លំដោយជុំវិញសំណួរអំពី 5G ព្រមទាំងមានរចនាបថ ពាក្យពេចន៍ និងអំណះអំណាងពេញលេញ។ គោលបំណងនៃបទនិពន្ធចង់បង្ហាញថាតើ 5G ជាអ្វី? តើយើងដឹងអ្វីខ្លះអំពី 5G និងឥទ្ធិពលដែលមានលើជីវិតរបស់យើងយ៉ាងដូចម្តេច? នេះជាអត្ថបទដែលបានបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា (CD-Center)។







អត្ថបទនិពន្ធជំនួយស្មារតីបង្ហោះជាសាធារណៈនៅលើបណ្តាញសង្គមហ្វេសប៊ុក របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ស្តីអំពីអ្វីគ្រប់យ៉ាងដែលអ្នកគួរដឹងពី 5G និង អក្ខរកម្មឌីជីថល , រូបភាពហ្វេសប៊ុក CD-Center ។

## ៤.២ របៀបតែងនិពន្ធក្នុងយុគសម័យឌីជីថល

របៀបតែងតែងនិពន្ធក្នុងយុគសម័យឌីជីថល មិនទាន់មានការកំណត់ជាក់លាក់នោះទេ។ បទនិពន្ធតែងឡើងគឺអាស្រ័យទៅលើភាពប៉ិនប្រសប់របស់អ្នកនិពន្ធ ព្រមទាំងសមត្ថភាពយល់ដឹងពីការវិវត្តន៍ថ្មីៗនៃដំណើរបច្ចេកវិទ្យានៅ

ក្នុងសង្គម។ អ្នកនិពន្ធត្រូវមានសិល្បៈក្នុងការប្រើប្រាស់ភាសា ឃ្លាប្រយោគ ចេះរៀបលំដាប់លំដោយនៃប្រធានបទ ឬអត្ថបទដែលខ្លួនចង់បង្ហាញ។ អ្វីៗគ្រប់យ៉ាងអាស្រ័យលើគំនិតរបស់អ្នកនិពន្ធ និងវិធីបង្ហាញរបស់អ្នកនិពន្ធ។

**១. អត្ថបទត្រូវបរិយាយតាមលំដាប់លំដោយគំនិត ឬលំហូរសាច់រឿង** : នេះជាការបង្ហាញពីវិធីគិតរបស់អ្នកនិពន្ធមានភាពច្បាស់លាស់ មានការរៀបត្រឹមត្រូវ អ្នកអានមានទំនុកចិត្ត និងងាយស្រួលយល់ខ្លឹមសារ។ មិនតែប៉ុណ្ណោះនៅក្នុងបទនិពន្ធត្រូវប្រើភាសាសាមញ្ញ ឃ្លានិងប្រយោគងាយយល់បំផុត ដែលអាចបង្ហាញពីគោលបំណង ឬខ្លឹមសារធ្វើឲ្យអ្នកអានស្វែងយល់បានលឿនរហ័ស។

**២. ប្រវែងអត្ថបទបទនិពន្ធ** : បើនិយាយពីប្រវែងរបស់អត្ថបទ ឬបទនិពន្ធក្នុងសម័យទំនើប អាស្រ័យលើប្រធានបទនិងខ្លឹមសារអ្នកនិពន្ធចង់បង្ហាញ បើខ្លីល្មមក៏ល្អបំផុត មិនធ្វើឱ្យអារម្មណ៍អ្នកអានធុញទ្រាន់នឹងគំនិតវែងអន្លាយ។

**៣. ការប្រើប្រាស់រូបភាព** : ក្រៅពីអត្ថបទ បទនិពន្ធគួរប្រើប្រាស់រូបភាពពន្យល់បន្ថែម ជំនួសឱ្យការអត្ថាធិប្បាយតែមួយមុខ។ ការប្រើប្រាស់រូបភាពក្នុងបទនិពន្ធជាការបន្ថែមសម្រស់ឱ្យអត្ថបទមានភាពទាក់ទាញមួយកម្រិតទៀតពីអ្នកអាន ឬអ្នកទទួលខ្លឹមសារ។ នៅពេលខ្លះរូបភាពអាចបង្ហាញព័ត៌មានបានច្រើនជាងការពណ៌នា ហើយរូបភាពជាភស្តុតាងជាក់លាក់ ធ្វើឱ្យអ្នកអានកាន់តែជឿជាក់អ្នកនិពន្ធ ប៉ុន្តែត្រូវប្រាកដពីប្រភពរូបភាពក្នុងអត្ថបទរបស់ខ្លួន។

**៤. ទីកន្លែងតែងនិពន្ធ** : តើទីណាដែលអាចតែងនិពន្ធបាននៅក្នុងសម័យទំនើប? ចម្លើយនៅពេលនេះ ទីណាក៏ជាកន្លែងដែលអាចតែងនិពន្ធបានដែរ ដោយសារមនុស្សប្រើប្រាស់ឧបករណ៍ឌីជីថលក្នុងការបង្កើតបទនិពន្ធ។ ពេលនេះគ្រាន់តែមានស្មាតហ្វូនមួយ ថតរូបភាព ឬទាញយករូបភាពមួយសន្លឹកភ្ជាប់ដោយការសរសេរខ្លឹមសារអ្វីមួយ រួចបង្ហោះលើអ៊ីនធឺណេត ឬបង្ហោះនៅលើទំព័រហ្វេសប៊ុកនោះ ក៏ជាការតែងនិពន្ធមួយបានដែរ។

**៥. អំណះអំណាង និងតំណភ្ជាប់** : ក្រៅពីនិយាយដោយសំអាងលើគំនិតសមហេតុផល ការគិតបែបតក្កវិទ្យា ការតែងនិពន្ធក្នុងយុគសម័យទំនើប ទាមទារអ្នកនិពន្ធមានអំណះអំណាងច្បាស់លាស់បន្ថែមទៀតលើសំណេររបស់ខ្លួន។ ការប្រមូលផ្តុំព័ត៌មានអំណះអំណាងបានគ្រប់ពេល គ្រប់ទីកន្លែងនេះ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានប្រសាសន៍ថា៖ "បើយើងចុចGoogle ព័ត៌មានទាំងអស់នៅលើហ្នឹងហើយ ប៉ុន្តែដើម្បីទាញយកផលប្រយោជន៍ពីហ្នឹងបាន ទាល់តែយើងចេះផ្សាភ្ជាប់ចំណុចផ្សេងៗនៃព័ត៌មានទាំងអស់បង្កើតជាខនថេនថ្មី (Create New Content) ហើយប្រើប្រាស់វាឱ្យមានប្រយោជន៍[8]"។

[8] ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានប្រសាសន៍នៅបាឋកថាសាធារណៈសម្រាប់កិច្ចសន្ទនា កម្ពុជាឧស្សាហកម្ម ៤.០ ក្រោមប្រធានបទ «អក្ខរកម្មឌីជីថលក្នុងបរិបទកម្ពុជាឧស្សាហកម្ម ៤.០» ថ្ងៃទី០៨ តុលា ២០១៩, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

សម័យឌីជីថលមាន មានប្រភពព័ត៌មានពាក់ព័ន្ធជាច្រើនដែលអ្នកនិពន្ធអាចស្វែងរកបាន ដើម្បីគាំទ្រស្នាដៃតែងនិពន្ធរបស់ខ្លួនឱ្យកាន់តែប្រសើរ។ តំណភ្ជាប់ (Link) ជាចំណុចសំខាន់នៅក្នុងអត្ថបទតែងនិពន្ធសម័យឌីជីថលនេះ ព្រោះតំណភ្ជាប់អាចឱ្យអ្នកអានស្វែងរកព័ត៌មានបន្ថែម ឬអានលម្អិតនៅលើអត្ថបទផ្សេងទៀត។ ការប្រើប្រាស់តំណភ្ជាប់ក្នុងអត្ថបទ មិនមែនមានន័យថាអ្នកនិពន្ធអន់ ឬលួចគំនិតរបស់អ្នកដទៃនោះទេ។ ការតែងនិពន្ធនៅលើឌីជីថលប្រើតំណភ្ជាប់កាន់តែច្រើន មានន័យថាអំណះអំណាងរបស់អ្នកនិពន្ធកាន់តែរឹងមាំ។

អ្នកនិពន្ធយុគសម័យឌីជីថល កុំបារម្ភពីការបង្ហាញតំណភ្ជាប់ប្រភពព័ត៌មានឱ្យអ្នកអានដឹង ឬខ្លាចអ្នកអានស្គាល់ប្រភពឯកសារដើម។ ព័ត៌មានរាល់ថ្ងៃសម្បូរបែប អ្នកនិពន្ធសម័យទំនើបត្រូវពឹងអាស្រ័យផ្អែកហេតុផលច្បាស់លាស់ពីឯកសារស្រាវជ្រាវ បុគ្គលសំខាន់ៗ និងស្ថាប័នជំនាញ។ តាមរយៈតំណភ្ជាប់ដែលអ្នកនិពន្ធប្រើនេះ ក៏ជាចំណែកមួយសំខាន់ជួយអ្នកអាន មានសមត្ថភាពអានជាអន្តរអត្ថបទ។

**៦. ឯកសារយោង និងកម្មសិទ្ធិបញ្ញា** : សតវត្សរ៍ទី២១នេះ ការតែងនិពន្ធ ឬបង្កើតខ្លឹមសារថ្មីគោរពដល់ប្រភពឯកសារ អ្នកនិពន្ធ អ្នកបង្កើតស្នាដៃគ្រប់ទម្រង់ ជាការរួមចំណែកលើកកម្ពស់កម្មសិទ្ធិបញ្ញា។ ការគោរពកម្មសិទ្ធិបញ្ញាជាប្រការសំខាន់ដែលអ្នកនិពន្ធមិនគួរមើលរំលង។ ការលួចចម្លងគំនិងអ្នកដទៃដោយគ្មានការអនុញ្ញាត ការដកស្រង់លួចលាក់ប្រភព អាចមានឈ្មោះជាចោរ ឬប្រព្រឹត្តបទល្មើសរំលោភលើកម្មសិទ្ធិបញ្ញា សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ នៅកម្ពុជាមានច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដូច្នេះហើយរាល់អត្ថបទតែងនិពន្ធទាំងអស់នៅសម័យឌីជីថល ត្រូវតែមានប្រភពច្បាស់លាស់ គោរពកម្មសិទ្ធិបញ្ញាដាច់ខាត។ អ្នកនិពន្ធមិនប្រកាន់ខ្ជាប់ក្រមសីលធម៌ និងវិជ្ជាជីវៈ ការតែងនិពន្ធនោះនឹងបរាជ័យជាក់ជាមិនខាននៅក្នុងយុគសម័យនៃបច្ចេកវិទ្យា ត្បិតបច្ចេកវិទ្យាអាចអាន អាចស្តាប់ អាចមើលដឹងស្នាដៃរបស់អ្នកនិពន្ធបានគ្រប់ពេលវេលា។

## ៤.៣ ការបោះពុម្ពផ្សាយអត្ថបទតែងនិពន្ធក្នុងសម័យឌីជីថល

ការតែងនិពន្ធនៅក្នុងយុគសម័យទំនើប ប្រើប្រាស់ឧបករណ៍ឌីជីថលជាមធ្យោបាយក្នុងការបង្កើតស្នាដៃ មានដូចជាបទនិពន្ធសំណេរ, សៀវភៅ, សំឡេង, វីដេអូ, រូបភាព, ការចែករំលែកគំនិតជំនួយស្មារតី, ក៏ត្រូវបោះពុម្ពផ្សាយនៅឌីជីថលដែរ។ តើអ្វីជាការបោះពុម្ពផ្សាយនៅលើឌីជីថល? ការបោះពុម្ពផ្សាយនៅលើឌីជីថល មានន័យថា អ្នកអានសម័យទំនើប អាចទាញយកស្នាដៃទាំងនោះមកអានបាន តាមរយៈការប្រើប្រាស់ឧបករណ៍ឌីជីថលដែលមានភ្ជាប់នឹងអ៊ីនធឺណេត។ ស្នាដៃទាំងនោះ អាចមាននៅលើ Google, គេហទំព័រ Wikipedia, Amazon, Alibaba, Airbnb, Personal Blog, និងអាចរកបាននៅលើបណ្តាញសង្គមគ្រប់ទម្រង់។ ដូច្នេះហើយអ្នកនិពន្ធត្រូវប្រាកដថា ការបោះពុម្ពស្នាដៃតែងនិពន្ធទាំងនេះ អាចអានបាននៅក្នុងឧបករណ៍ឌីជីថល មានឃីនដល (Kindle), កុំព្យូទ័រ, ស្មាតហ្វូន, អ៊ីនធឺណេត (Internet), និងយូធូប (YouTube) ជាដើម។

សរុបជារួមមកវិញ ការតែងនិពន្ធក្នុងយុគសម័យទំនើប ( ឌីជីថល ) គ្រប់ទម្រង់ ជាការបង្កើតស្នាដៃថ្មី ឬបង្កើតខ្លឹមសារថ្មីដោយគំនិតច្នៃប្រឌិត ហើយចែករំលែកដល់អ្នកអាននៅលើឧបករណ៍ឌីជីថល។ ទន្ទឹមគ្នានេះ ការតែងនិពន្ធនៅលើឌីជីថលមានក៏តម្លៃដូចការតែងនិពន្ធសៀវភៅបោះពុម្ពដែរ  ប៉ុន្តែខុសគ្នាត្រង់ការតែងនិពន្ធលើក្រដាសពិបាកចែករំលែក ពិបាកចល័ត និងចំណាយពេលច្រើនក្នុងការស្វែងរកអាន។ ចំណែកការតែងនិពន្ធនៅលើឌីជីថលងាយស្រួលអាន, ចំណេញពេលវេលា, ព្រមទាំងចែករំលែកបានទូលំទូលាយនៅលើអ៊ីនធឺណេត។

កាលបើនិយាយពីរបៀបតែងនិពន្ធនៅក្នុងយុគសម័យឌីជីថល វាជាសេរីភាពរបស់អ្នកនិពន្ធក្នុងការបង្កើតខ្លឹមសារ ខណៈក្បួនឬរៀបតែងនិពន្ធនៃទម្រង់និពន្ធថ្មីនេះ មិនទាន់មានការកំណត់ច្បាស់លាស់នៅឡើយ។ សំណេរ ឬបទនិពន្ធដែលល្អនៅពេលនេះ អាស្រ័យលើសមត្ថភាពរបស់អ្នកនិពន្ធដែលផ្តល់ខ្លឹមសារដល់អ្នកអាន ហើយធានាថាគុណភាពនៃខ្លឹមសារ បម្រើដល់តម្រូវការរបស់អ្នកអាន និងបម្រើផលប្រយោជន៍សង្គមជាក់ស្តែង។

## ៥. សេចក្តីសន្និដ្ឋាន

ខ្លឹមសារសំណេរនិយាយពី "ការតែងនិពន្ធក្នុងយុគសម័យទំនើប"នេះ នឹងផ្តល់ជាទស្សនទានចូលរួមគំនិតក្នុងការតែងនិពន្ធ ឬបង្កើតខ្លឹមសារនៅលើឌីជីថលឱ្យបានត្រឹមត្រូវនិងកាន់តែទូលំទូលាយសម្រាប់អ្នកប្រើប្រាស់ឌីជីថលនៅកម្ពុជា។ ត្បិតគ្រប់គ្នាសុទ្ធតែមានសេរីភាពតែងនិពន្ធ ប៉ុន្តែការតែងនិពន្ធដែលមិនមានមូលដ្ឋានត្រឹមត្រូវ មិនបានគិតដល់តម្រូវការរបស់អ្នកអាន ក៏ជាចំណុចដែលអ្នកនិពន្ធខ្លឹមសារត្រូវពិចារណាដែរ។ តាមរយៈអត្ថបទសំណេរនេះ មិនបានកំណត់ឱ្យអ្នកអានត្រូវធ្វើតាមទាំងស្រុងនោះទេ ព្រោះការសិក្សាស្រាវជ្រាវនៅលើសម័យឌីជីថលអាចឱ្យអ្នកអានពើបប្រទះនឹងគំហើញនៃការស្រាវជ្រាវថ្មីៗជាបន្តបន្ទាប់។ ការអានលើឌីជីថលនិងការអានសៀវភៅមានគុណសម្បត្តិដូចគ្នាក្នុងការផ្តល់ចំណេះដឹងដល់អ្នកអាន។ អំណាននៅលើឌីជីថ លឿនរហ័ស សម្បូរបែប ងាយស្រួលចែករំលែក រីឯអំណានលើសៀវភៅអាចរកអានបានដោយមិនចាំបាច់ប្រើប្រាស់អ៊ីនធឺណេត[៩]។ ទំនងនៅក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ នឹងចូលមកដល់នៅពេលខាងមុខ មធ្យោបាយទទួលចំណេះដឹងស្ទើរទាំងអស់ ត្រូវពឹងអាស្រ័យទៅលើការប្រើប្រាស់ឌីជីថលជាមូលដ្ឋាន។ អាស្រ័យដូច្នេះ ការយល់ដឹង និង មានលទ្ធភាពប្រើប្រាស់ឌីជីថលបានទូលំទូលាយ ( អក្ខរកម្មឌីជីថល ), ការចែករំលែកព័ត៌មានបានត្រឹមត្រូវ, និងការទទួលចំណេះដឹងមានគុណភាព, ត្រូវចាប់ផ្តើមពីការអប់រំបែបឌីជីថលសម្រាប់ទាំងអស់គ្នា៕

[9] ( ស្មេរ ) អំនានលើសៀវភៅ មានគុណសម្បត្តិដោយឡែកពីការអានសៀវភៅនៅលើឧបករណ៍ឌីជីថល ដោយសារសៀវភៅជួយសុខភាពភ្នែក និងស្មារតី, មិនមានការរំខានពីការផ្សព្វផ្សាយពាណិជ្ជកម្ម (Ad), អាចរក្សាទុកនៅទីកន្លែងជាក់លាក់ដែលអាចស្វែងរកបានដោយមិនចាំបាច់ត្រូវការអ៊ីនធឺណេត, និងជួយបង្កើនទំនាក់ទំនងដោយផ្ទាល់រវាងមនុស្សនិងមនុស្សនៅក្នុងសង្គម។

## ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០”។ តំណភ្ជាប់ [http://moeys.gov.kh/index.php/kh/policies-and-strategies/3277.html#.Xi1bS4VOLIW] ។

មុន្នីវិសាល, តាន់. (២០១៩). បដិវត្តន៍ឧស្សាហកម្មទី៤ (ឧស្សាហកម្ម៤.០),មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ តំណភ្ជាប់ ឯកសារភាសាខ្មែរ [http://cd-center.org/fourth-industrial-revolution-industry-4-0/ ]។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា. (២០១៩). កិច្ចសន្ទនាកម្ពុជាឧស្សាហកម្ម៤.០ (ហេតុអ្វីកម្ពុជាជាឧស្សាហកម្ម៤.០)។ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ តំណភ្ជាប់យូធូប [ https://youtu.be/1euw9BCyaTU ]។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា. (២០១៩). ឯកសារជំនួយស្មារតីស្តីពី ទីក្រុងឆ្លាតវៃ ។

រតនធីតា, គង់. (២០១៩). (ជំនួយស្មារតី) ស្វែងយល់ពីសេដ្ឋកិច្ចឌីជីថល។ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ តំណភ្ជាប់ ឯកសារភាសាខ្មែរ [http://cd-center.org/understanding-digital-economy/ ]

សឿង, ភារៈ. (២០១៩). កម្ពុជា និងបដិវត្តន៍ឧស្សាហកម្មទី៤ ៖ ឱកាសនិងការប្រឈម។ វិទ្យុបារាំងអន្តរជាតិ ខេមរៈភាសា (RFI Khmer) ។ គេហទំព័រព័ត៌មានវិទ្យុបារាំង [http://m.km.rfi.fr/daily-event-16-06-2019]។

ទីស្តីការគណៈរដ្ឋមន្ត្រី. (២០១៩), សម្តេចតេជោ ហ៊ុន សែន បើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៩ ។ តំណគេហទំព័រព័ត៌មានទីស្តីការគណៈរដ្ឋមន្ត្រី https://pressocm.gov.kh/archives/50741 ។

Petrillo, Antonella. (២០១៨) ជំពូក១ បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤: បច្ចុប្បន្នភាព, បញ្ហាប្រឈម, និងឱកាស ។ សូមចុចតំណភ្ជាប់នៅពាក្យនេះ តំណភ្ជាប់គេហទំព័រ។

ប្រវត្តិសាស្ត្រ (History). (២០១៩). បដិវត្តន៍ឧស្សាហកម្ម។ តំណភ្ជាប់យូធូប [https://www.history.com/topics/industrial-revolution/industrial-revolution]។

សៀវភៅកំណាព្យចំណាងជើង (ឆ្នាំ២០១៧).“ការវិវត្តផ្នត់គំនិតក្នុងសម័យឌីជីថល” មណ្ឌលព័ត៌មានស្ត្រីកម្ពុជា។ តំណភ្ជាប់ [http://www.wmc.org.kh/samnoun-prome-khmer-wmc-2017/]

ស្ថិតិអ្នកប្រើប្រាស់ទូរស័ព្ទចល័តនៅកម្ពុជា, (២០១៩), Techkhmer, តំណភ្ជាប់នៅទីនេះ ។

## ឯកសារយោងនៅលើគេហទំព័រជាភាសាបរទេស :

Digital Stories: A 21st-Century Communication Tool for the English Language Classroom។

What is Digital Writing？ [https://sites.google.com/site/odu307fall2012/] ។

Developing Digital Writing Skill: [https://www.onlinecollege.org/developing-digital-writing-skills/] ។

Digital Writing: [http://w350digitalwriting.wikidot.com/] ។

Digital Writing and Research Lab: [https://en.wikipedia.org/wiki/Digital_Writing_and_Research_Lab។

Digital Writing Tools: [https://link.springer.com/article/10.1007/s10639-018-9844-x]

Persona in Digital Writing: [http://w350digitalwriting.wikidot.com/landon-s-page។]